**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

## សូមគោរពជូន

## ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប
## អនុប្រធានទី១ នៃរដ្ឋសភាជាតិ

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ ខ្ញុំសូមសម្តែងនូវការអបអរសាទរដ៏កក់ក្តៅបំផុតជូន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** ក្នុងឱកាសដែល **ឯកឧត្តម** ត្រូវបានរដ្ឋសភា នីតិកាលទី៦ បោះឆ្នោតជ្រើសតាំងជា **អនុប្រធានទី១ នៃរដ្ឋសភាជាតិ**។

ក្នុងឱកាសប្រកបដោយមោទនភាពនេះ **ឯកឧត្តម** ពិតជាមានកិត្តិយសស័ក្តិសមនឹងទទួលបានការតែងតាំងជា «**អនុប្រធានទី១ នៃរដ្ឋសភាជាតិ**» ដែលជាសក្ខីភាពឆ្លុះបញ្ចាំងពីសមត្ថភាពដឹកនាំ ភាពឈ្លាសវៃ ប៉ិនប្រសប់ ក្នុងកិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីសម្រេចការងារប្រកបដោយគតិបណ្ឌិត និងទេពកោសល្យខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍ជាតិ និងប្រជាជន។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមមេត្តាជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គលគ្រប់ប្រការជូន **ឯកឧត្តម និងលោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមមានជន្មាយុយឺនយូរ សុខុមាលភាពបរិបូរណ៍ និងសម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់គ្រប់ភារកិច្ចការងារ សំដៅរួមចំណែកថែរក្សាសុខសន្តិភាព ស្ថិរភាព ជូនប្រទេសជាតិប្រកបដោយវឌ្ឍនភាពរីកចម្រើន សម្បូណ៌សប្បាយ រុងរឿង លើគ្រប់វិស័យជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ៦ រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញថ្ងៃទី២៥ ខែវិច្ឆិកាឆ្នាំ២០២១

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh